ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..២៥៤..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាកនាំចេញលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ២៦៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៥៦២ អនក្រ.បក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី ១

ការកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូល

មាត្រា ១.- ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលចំនួន ៩៥ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានដូចខាងក្រោម÷

- បន្ថយអត្រាពន្ធគយពី ៧% ទៅ 0% លើមុខទំនិញសៀវភៅអាន ចំនួន ០៧ បន្ទាត់ពន្ធ ក្នុងទីតាំងរងលេខ ៤៩០២.១០.០០ ៤៩០២.៩០.១០ ៤៩០២.៩០.៩០ ៤៩០៤.០០.០០ ៤៩០៥.៩១.០០ ៤៩១១.៩០.១០ និងទីតាំងរងលេខ ៤៩១១.១០.៩០ ។

- បន្ថយអត្រាពន្ធគយពី ៧% ទៅ 0% លើមុខទំនិញប្រដាប់ប្រដាក្មេងលេង ចំនួន ១៣ បន្ទាត់ពន្ធ ក្នុងទីតាំងរងលេខ ៩៥០៣.០០.១០ ៩៥០៣.០០.២១ ៩៥០៣.០០.២២ ៩៥០៣.០០.២៩ ៩៥០៣.០០.៣០ ៩៥០៣.០០.៤០ ៩៥០៣.០០.៥០ ៩៥០៣.០០.៦០ ៩៥០៣.០០.៧០ ៩៥០៣.០០.៩១ ៩៥០៣.០០.៩២ ៩៥០៣.០០.៩៣ និងទីតាំងរងលេខ ៩៥០៣.០០.៩៩។

- បន្ថយអត្រាពន្ធគយពី ១៥% ទៅ ៧% លើមុខទំនិញកុំព្យូទ័រនិងគ្រឿងបន្លាប់បន្សំ ចំនួន ៦៧ បន្ទាត់ពន្ធ ក្នុងទីតាំងរងលេខ ៨៤៧១.៣០.១០ ៨៤៧១.៣០.២០ ៨៤៧១.៣០.៩០ ៨៤៧១.៤១.១០ ៨៤៧១.៤១.៩០ ៨៤៧១.៤៩.១០ ៨៤៧១.៤៩.៩០ ៨៤៧១.៥០.១០ ៨៤៧១.៥០.៩០ ៨៤៧១.៦០.៣០ ៨៤៧១.៦០.៤០ ៨៤៧១.៦០.៩០ ៨៤៧១.៧០.១០ ៨៤៧១.៧០.២០ ៨៤៧១.៧០.៣០ ៨៤៧១.៧០.៤០ ៨៤៧១.៧០.៥០ ៨៤៧១.៧០.៩១ ៨៤៧១.៧០.៩៩ ៨៤៧១.៨០.១០ ៨៤៧១.៨០.៧០ ៨៤៧១.៨០.៩០ ៨៤៧១.៩០.១០ ៨៤៧១.៩០.២០ ៨៤៧១.៩០.៩០ ៨៤៧៣.៣០.១០ ៨៤៧៣.៣០.៩០ ៨៤៧៣.៥០.១១ ៨៥២៣.២៩.១១ ៨៥២៣.២៩.២១ ៨៥២៣.២៩.២៩ ៨៥២៣.២៩.៣១ ៨៥២៣.២៩.៣៣ ៨៥២៣.២៩.៤១ ៨៥២៣.២៩.៤២ ៨៥២៣.២៩.៤៣ ៨៥២៣.២៩.៥១ ៨៥២៣.២៩.៥២ ៨៥២៣.២៩.៦១ ៨៥២៣.២៩.៦២ ៨៥២៣.២៩.៦៣ ៨៥២៣.២៩.៧១ ៨៥២៣.២៩.៨១ ៨៥២៣.២៩.៨៣ ៨៥២៣.២៩.៨៤ ៨៥២៣.២៩.៩១ ៨៥២៣.២៩.៩៣ ៨៥២៣.២៩.៩៥ ៨៥២៣.៤១.១០

៨៥២៣.៤៤.១២	៨៥២៣.៤៤.១៤	៨៥២៣.៤៤.៤២	៨៥២៣.៤៤.៤៣	៨៥២៣.៥១.១១
៨៥២៣.៥១.២១	៨៥២៣.៥១.៣០	៨៥២៣.៥៤.២១	៨៥២៣.៥៤.៤០	៨៥២៣.៨០.៥១
៨៥២៣.៨០.៩២	៨៥២៨.៤១.១០	៨៥២៨.៤១.២០	៨៥២៨.៥១.១០	៨៥២៨.៥១.២០
៨៥២៨.៥១.៣០	៨៥២៨.៦១.១០	និងទីតាំងរងលេខ	៨៥២៨.៦១.៩០។	

- បន្ថយអត្រាពន្ធគយពី ៣៥% ទៅ ១៥% លើមុខទំនិញកុំព្យូទ័រនិងគ្រឿងបន្ទាប់បន្សំ ចំនួន ០៣ បន្ទាត់ពន្ធ ក្នុងទីតាំងរងលេខ ៨៥០៤.៥០.១០ ៨៥០៧.៦០.១០ និងទីតាំងរងលេខ ៨៥០៧.៨០.៩១។
- ដំឡើងអត្រាពន្ធគយពី 0% ទៅ ៧% លើមុខទំនិញដែកគ្រោងអាលុយមីញ៉ូម ចំនួន ០៥ បន្ទាត់ពន្ធ ក្នុងទីតាំងរងលេខ ៧៦០៤.១០.៩០ ៧៦០៤.២១.១០ ៧៦០៤.២១.៩០ ៧៦០៤.២៩.៣០ និងទីតាំងរងលេខ ៧៦០៤.២៩.៩០។

ជំពូកទី ២
ការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

មាត្រា ២.-ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញកេសជ្ជៈមានជាតិស្ករឬមួយចំនួន ដូចខាងក្រោម÷

- ដំឡើងអត្រាអាករពិសេសពី ២៥% ទៅ ៣០% លើមុខទំនិញស្រាបៀរចំនួន ០២បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២២០៣.០០.១០ និងទីតាំងរងលេខ ២២០៣.០០.៩០។
- ដំឡើងអត្រាអាករពិសេសពី ២០% ទៅ ៣៥% លើមុខទំនិញស្រាចំនួន ៤៣បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ២២០៤.១០.០០ ២២០៤.២១.១១ ២២០៤.២១.១៣ ២២០៤.២១.១៤ ២២០៤.២១.២១ ២២០៤.២១.២២ ២២០៤.២៩.១១ ២២០៤.២៩.១៣ ២២០៤.២៩.១៤ ២២០៤.២៩.២១ ២២០៤.២៩.២២ ២២០៤.៣០.១០ ២២០៤.៣០.២០ ២២០៥.១០.១០ ២២០៥.១០.២០ ២២០៥.៩០.១០ ២២០៥.៩០.២០ ២២០៦.០០.១០ ២២០៦.០០.២០ ២២០៦.០០.៣០ ២២០៦.០០.៤០ ២២០៦.០០.៩១ ២២០៦.០០.៩៩ ២២០៧.១០.០០ ២២០៧.២០.១១ ២២០៧.២០.១៩ ២២០៧.២០.៩០ ២២០៨.២០.៥០ ២២០៨.២០.៩០ ២២០៨.៣០.០០ ២២០៨.៤០.០០ ២២០៨.៥០.០០ ២២០៨.៦០.០០ ២២០៨.៧០.០០ ២២០៨.៩០.១០ ២២០៨.៩០.២០ ២២០៨.៩០.៣០ ២២០៨.៩០.៤០ ២២០៨.៩០.៥០ ២២០៨.៩០.៦០ ២២០៨.៩០.៧០ ២២០៨.៩០.៨០ និងទីតាំងរងលេខ ២២០៨.៩០.៩០។

មាត្រា ៣.- ត្រូវបានដំឡើងអត្រាអាករពិសេសពី ១៥% ទៅ ២០% លើមុខទំនិញបារីចំនួន ០៣ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៤០២.២០.១០ ២៤០២.២០.២០ និងទីតាំងរងលេខ ២៤០២.២០.៩០។

មាត្រា ៤.-ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញផលិតផលគេលសិលាមួយចំនួន ដូចខាងក្រោម÷

- ដំឡើងពី 0% ទៅ ១៥% លើមុខទំនិញសារធាតុបន្ថែមសម្រាប់ប្រេងសាំង ចំនួន ០១បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៩០៩.១៩.០០។
- ដំឡើងពី ៥% ទៅ២៥% លើមុខទំនិញសាំងក្រអូបចំនួន ០១បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៧១០.១២.៤០។
- ដំឡើងពី ៥% ទៅ២៥% លើមុខទំនិញវត្ថុធាតុដើមសម្រាប់លាយជាមួយប្រេងសាំង ចំនួន ០១បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៧១០.១២.៧០។

- ដំឡើងពី ១០% ទៅ ២០% លើមុខទំនិញវត្ថុធាតុដើមសម្រាប់ផលិតប្រេងរំអិលចំនួន ០១បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៧១០.១៩.៤១។
- ដំឡើងពី ១០% ទៅ ២៥% លើមុខទំនិញសារធាតុបន្ថែមសម្រាប់ប្រេងរំអិលចំនួន ០៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៣៨១១.២១.១០ ៣៨១១.២១.៩០ និង ៣៨១១.២៩.០០។

មាត្រា ៥.- ត្រូវបានដំឡើងអត្រាអាករពិសេសពី ០% ទៅ១០% លើមុខទំនិញផលិតផលកញ្ចក់ជាគ្រឿងសំណង់ចំនួន ២០ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ៧០០៣.១២.១០

៧០០៣.១២.២០	៧០០៣.១២.៩០	៧០០៣.១៩.១០	៧០០៣.១៩.៩០
៧០០៣.២០.០០	៧០០៣.៣០.០០	៧០០៤.២០.១០	៧០០៤.២០.៩០
៧០០៤.៩០.១០	៧០០៤.៩០.៩០	៧០០៥.១០.១០	៧០០៥.១០.៩០
៧០០៥.២១.១០	៧០០៥.២១.៩០	៧០០៥.២៩.១០	៧០០៥.២៩.៩០
៧០០៥.៣០.០០	៧០០៦.០០.១០	និងទីតាំងរងលេខ	៧០០៦.០០.៩០។

មាត្រា ៦.- ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញគ្រឿងអេឡិចត្រូនិចមួយចំនួន ដូចខាងក្រោម÷

- ដំឡើងពី ០% ទៅ ១០% លើមុខទំនិញគ្រឿងអេឡិចត្រូនិច ចំនួន ៥០ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ

៨៤១៨.៦៩.៤១	៨៤១៨.៩៩.៤០	៨៤៥០.៩០.១០	៨៤៥១.៩០.១១
៨៤៧៦.២១.០០	៨៤៧៦.៨១.០០	៨៥១៨.៣០.៥១	៨៥១៨.៤០.៣០
៨៥១៨.៤០.៤០	៨៥១៨.៥០.២០	៨៥១៩.២០.១០	៨៥១៩.២០.២០
៨៥១៩.៣០.០០	៨៥១៩.៥០.០០	៨៥១៩.៨១.១០	៨៥១៩.៨១.៦៩
៨៥១៩.៨១.៧៩	៨៥១៩.៨៩.២០	៨៥១៩.៨៩.៩០	៨៥២២.១០.០០
៨៥២២.៩០.២០	៨៥២២.៩០.៩២	៨៥២២.៩០.៩៣	៨៥២២.៩០.៩៩
៨៥២៧.១៣.១០	៨៥២៧.១៩.១១	៨៥២៧.១៩.៩១	៨៥២៧.៩១.១០
៨៥២៧.៩១.៩០	៨៥២៧.៩២.១០	៨៥២៧.៩២.៩១	៨៥២៧.៩២.៩៩
៨៥២៧.៩៩.១០	៨៥២៧.៩៩.៩១	៨៥២៨.៦៩.១០	៨៥២៨.៧១.១១
៨៥២៨.៧១.៩១	៨៥២៨.៧១.៩៩	៨៥២៨.៧២.១០	៨៥២៨.៧២.៩១
៨៥២៩.៩០.២០	៨៥២៩.៩០.៥១	៨៥២៩.៩០.៥២	៨៥២៩.៩០.៥៣
៨៥២៩.៩០.៥៤	៨៥២៩.៩០.៥៥	៨៥២៩.៩០.៥៩	៨៥២៩.៩០.៩១
៨៥២៩.៩០.៩៤	និងទីតាំងរងលេខ ៨៥២៩.៩០.៩៩ ។		

- ដំឡើងពី ១០% ទៅ ២៥% លើមុខទំនិញជាគ្រឿងអេឡិចត្រូនិច ចំនួន ០២ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៤១៥.២០.៩០ និងទីតាំងរងលេខ ៨៥២៧.២៩.០០។
- បន្ថយពី ១០% ទៅ ០% លើមុខទំនិញជាកុំព្យូទ័រនិងគ្រឿងបន្ទាប់បន្សំ ចំនួន ៣២ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ

៨៤៧១.៣០.១០	៨៤៧១.៣០.២០	៨៤៧១.៣០.៩០	៨៤៧១.៤១.១០
៨៤៧១.៤១.៩០	៨៤៧១.៤៩.១០	៨៤៧១.៤៩.៩០	៨៤៧១.៥០.១០
៨៤៧១.៥០.៩០	៨៤៧១.៦០.៣០	៨៤៧១.៦០.៤០	៨៤៧១.៦០.៩០
៨៤៧១.៧០.១០	៨៤៧១.៧០.២០	៨៤៧១.៧០.៣០	៨៤៧១.៧០.៤០
៨៤៧១.៧០.៥០	៨៤៧១.៧០.៩១	៨៤៧១.៧០.៩៩	៨៤៧១.៨០.១០
៨៤៧១.៨០.៤០	៨៤៧១.៨០.៥០	៨៤៧១.៨០.៦០	៨៤៧១.៩០.១០
៨៤៧១.៩០.២០	៨៤៧១.៩០.៩០	៨៥២១.១០.១០	៨៥២៨.៤១.១០
៨៥២៨.៥១.២០	៨៥២៨.៥១.៣០	៨៥២៨.៦១.១០	និងទីតាំងរងលេខ ៨៥២៨.៦១.៩០ ។

មាត្រា ៧. - ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញទោចក្រយានយន្តមួយចំនួន ដូចខាងក្រោម÷

- ដំឡើងពី១០% ទៅ ១៥% លើមុខទំនិញទោចក្រយានយន្ត ចំនួន ០៧ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ៨៧១១.២០.៣១ ៨៧១១.២០.៣២ ៨៧១១.២០.៤៥ ៨៧១១.២០.៤៩ ៨៧១១.២០.៥១ ៨៧១១.២០.៥២ និងទីតាំងរងលេខ ៨៧១១.២០.៩០ ។

- ដំឡើងពី ១០% ទៅ ២០% លើមុខទំនិញទោចក្រយានយន្ត ចំនួន ០៤ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជា ជាធរមាន ក្នុងទីតាំងរងលេខ ៨៧១១.៣០.៣០ ៨៧១១.៣០.៩០ ៨៧១១.៤០.២០ និង ទីតាំងរងលេខ ៨៧១១.៤០.៩០ ។
- ដំឡើងពី ១០% ទៅ ២៥% លើមុខទំនិញទោចក្រយានយន្ត ចំនួន ០៥ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជា ជាធរមាន ក្នុងទីតាំងរងលេខ ៨៧១១.៥០.២០ ៨៧១១.៥០.៩០ ៨៧១១.២០.១០ ៨៧១១.៣០.១០ និង ទីតាំងរងលេខ៨៧១១.៤០.១០។

មាត្រា ៨.- ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន ដូចខាងក្រោម÷

- ដំឡើងពី ២៥% ទៅ ៣០% លើមុខទំនិញរថយន្តទេសចរណ៍ចំនួន ០៩ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជា ជាធរមាន ក្នុងទីតាំងរងលេខ ៨៧០៣.២១.១០ ៨៧០៣.២១.២២ ៨៧០៣.២១.២៣ ៨៧០៣.២១.២៤ ៨៧០៣.២១.២៩ ៨៧០៣.២១.៣១ ៨៧០៣.២១.៣៩ ៨៧០៣.២១.៩២ និងទីតាំងរងលេខ ៨៧០៣.២១.៩៩។

- ដំឡើងពី ៥០% ទៅ៦០% លើមុខទំនិញរថយន្តទេសចរណ៍ចំនួន ៥២ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជា ជាធរមាន ក្នុងទីតាំងរងលេខ ៨៧០៣.២២.១១ ៨៧០៣.២២.១៩ ៨៧០៣.២២.២១ ៨៧០៣.២២.២៩ ៨៧០៣.២២.៩២ ៨៧០៣.២២.៩៩ ៨៧០៣.២៣.៤០ ៨៧០៣.២៣.៥១ ៨៧០៣.២៣.៥២ ៨៧០៣.២៣.៥៣ ៨៧០៣.២៣.៥៤ ៨៧០៣.២៣.៦១ ៨៧០៣.២៣.៦២ ៨៧០៣.២៣.៦៣ ៨៧០៣.២៣.៦៤ ៨៧០៣.២៣.៧១ ៨៧០៣.២៣.៧២ ៨៧០៣.២៣.៧៣ ៨៧០៣.២៣.៧៤ ៨៧០៣.២៣.៩១ ៨៧០៣.២៣.៩២ ៨៧០៣.២៣.៩៣ ៨៧០៣.២៣.៩៤ ៨៧០៣.៣១.១១ ៨៧០៣.៣១.១៩ ៨៧០៣.៣១.២០ ៨៧០៣.៣១.៥០ ៨៧០៣.៣១.៨១ ៨៧០៣.៣១.៨៩ ៨៧០៣.៣១.៩១ ៨៧០៣.៣១.៩៩ ៨៧០៣.៣២.៤២ ៨៧០៣.៣២.៤៣ ៨៧០៣.៣២.៤៤ ៨៧០៣.៣២.៤៩ ៨៧០៣.៣២.៥២ ៨៧០៣.៣២.៥៣ ៨៧០៣.៣២.៥៤ ៨៧០៣.៣២.៥៩ ៨៧០៣.៣២.៧១ ៨៧០៣.៣២.៧២ ៨៧០៣.៣២.៧៣ ៨៧០៣.៣២.៧៩ ៨៧០៣.៣២.៩២ ៨៧០៣.៣២.៩៣ ៨៧០៣.៣២.៩៤ ៨៧០៣.៣២.៩៩ ៨៧០៣.៣៣.៤៣ ៨៧០៣.៣៣.៤៤ ៨៧០៣.៣៣.៥៣ ៨៧០៣.៣៣.៥៤ និងទីតាំងរងលេខ ៨៧០៣.៣២.៦០ ។
- ដំឡើងពី ៥០% ទៅ ៦៥% លើមុខទំនិញរថយន្តទេសចរណ៍ ១៨ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជា ជាធរមាន ក្នុងទីតាំងរងលេខ ៨៧០៣.២៤.៤១ ៨៧០៣.២៤.៤៩ ៨៧០៣.២៤.៥១ ៨៧០៣.២៤.៥៩ ៨៧០៣.២៤.៨១ ៨៧០៣.២៤.៨៩ ៨៧០៣.២៤.៩១ ៨៧០៣.២៤.៩៩ ៨៧០៣.៣៣.៤៥ ៨៧០៣.៣៣.៤៩ ៨៧០៣.៣៣.៥៥ ៨៧០៣.៣៣.៥៩ ៨៧០៣.៣៣.៨១ ៨៧០៣.៣៣.៨៩ ៨៧០៣.៣៣.៩១ ៨៧០៣.៣៣.៩៩ ៨៧០៣.២៤.៧០ និងទីតាំងរងលេខ ៨៧០៣.៣៣.៧០ ។
- ដំឡើងពី ៣០% ទៅ ៤០% លើមុខទំនិញរថយន្តដឹកអ្នកដំណើរនិងដឹកទំនិញ ចំនួន ១៣៤ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៧០១.២០.១០ ៨៧០១.២០.៩០ ៨៧០១.៩០.៩០ ៨៧០២.១០.១០ ៨៧០២.១០.៤១ ៨៧០២.១០.៤៩ ៨៧០២.១០.៥០ ៨៧០២.១០.៦០ ៨៧០២.១០.៧១ ៨៧០២.១០.៧៩ ៨៧០២.១០.៨១ ៨៧០២.១០.៨៩ ៨៧០២.១០.៩០ ៨៧០២.៩០.១២ ៨៧០២.៩០.១៣ ៨៧០២.៩០.១៤ ៨៧០២.៩០.១៩ ៨៧០២.៩០.៩២ ៨៧០២.៩០.៩៣ ៨៧០២.៩០.៩៤ ៨៧០២.៩០.៩៥ ៨៧០២.៩០.៩៩ ៨៧០៤.១០.១៣ ៨៧០៤.១០.១៤ ៨៧០៤.១០.១៥ ៨៧០៤.១០.១៦ ៨៧០៤.១០.១៧ ៨៧០៤.១០.១៨ ៨៧០៤.១០.២៣ ៨៧០៤.១០.២៤ ៨៧០៤.១០.២៥ ៨៧០៤.១០.២៦

៨៧០៤.១០.២៧	៨៧០៤.១០.២៨	៨៧០៤.២១.១១	៨៧០៤.២១.១៩	៨៧០៤.២១.២១
៨៧០៤.២១.២៣	៨៧០៤.២១.២៤	៨៧០៤.២១.២៥	៨៧០៤.២១.២៩	៨៧០៤.២២.១១
៨៧០៤.២២.១៩	៨៧០៤.២២.២១	៨៧០៤.២២.២៣	៨៧០៤.២២.២៤	៨៧០៤.២២.២៥
៨៧០៤.២២.២៩	៨៧០៤.២២.៣១	៨៧០៤.២២.៣៩	៨៧០៤.២២.៤១	៨៧០៤.២២.៤៣
៨៧០៤.២២.៤៤	៨៧០៤.២២.៤៥	៨៧០៤.២២.៥១	៨៧០៤.២២.៥៩	៨៧០៤.២៣.១១
៨៧០៤.២៣.១៩	៨៧០៤.២៣.២១	៨៧០៤.២៣.២៣	៨៧០៤.២៣.២៤	៨៧០៤.២៣.២៥
៨៧០៤.២៣.២៩	៨៧០៤.២៣.៥១	៨៧០៤.២៣.៥៩	៨៧០៤.២៣.៦១	៨៧០៤.២៣.៦៣
៨៧០៤.២៣.៦៤	៨៧០៤.២៣.៦៥	៨៧០៤.២៣.៦៦	៨៧០៤.២៣.៦៩	៨៧០៤.២៣.៧១
៨៧០៤.២៣.៧៩	៨៧០៤.២៣.៨១	៨៧០៤.២៣.៨៣	៨៧០៤.២៣.៨៤	៨៧០៤.២៣.៨៥
៨៧០៤.២៣.៨៦	៨៧០៤.២៣.៨៩	៨៧០៤.៣១.១១	៨៧០៤.៣១.១៩	៨៧០៤.៣១.២១
៨៧០៤.៣១.២៣	៨៧០៤.៣១.២៤	៨៧០៤.៣១.២៥	៨៧០៤.៣១.២៩	៨៧០៤.៣២.១១
៨៧០៤.៣២.១៩	៨៧០៤.៣២.២១	៨៧០៤.៣២.២៣	៨៧០៤.៣២.២៤	៨៧០៤.៣២.២៥
៨៧០៤.៣២.២៩	៨៧០៤.៣២.៣១	៨៧០៤.៣២.៣៩	៨៧០៤.៣២.៤១	៨៧០៤.៣២.៤៣
៨៧០៤.៣២.៤៤	៨៧០៤.៣២.៤៥	៨៧០៤.៣២.៤៦	៨៧០៤.៣២.៤៩	៨៧០៤.៣២.៥១
៨៧០៤.៣២.៥៩	៨៧០៤.៣២.៦១	៨៧០៤.៣២.៦៣	៨៧០៤.៣២.៦៤	៨៧០៤.៣២.៦៥
៨៧០៤.៣២.៦៩	៨៧០៤.៣២.៧២	៨៧០៤.៣២.៧៩	៨៧០៤.៣២.៨១	៨៧០៤.៣២.៨៣
៨៧០៤.៣២.៨៤	៨៧០៤.៣២.៨៥	៨៧០៤.៣២.៨៦	៨៧០៤.៣២.៨៩	៨៧០៤.៣២.៩១
៨៧០៤.៣២.៩២	៨៧០៤.៣២.៩៣	៨៧០៤.៣២.៩៥	៨៧០៤.៣២.៩៦	៨៧០៤.៣២.៩៧
៨៧០៤.៣២.៩៨	៨៧០៤.៣២.៩៩	៨៧០៤.៩០.១០	៨៧០៤.៩០.៩១	៨៧០៤.៩០.៩២
៨៧០៤.៩០.៩៣	៨៧០៤.៩០.៩៤	៨៧០៤.៩០.៩៩	៨៧០៥.១០.០០	៨៧០៥.២០.០០
៨៧០៥.៤០.០០	និងទីតាំងរងលេខ	៨៧០៥.៩០.៩០។		

- ដំឡើងពី ១០% ទៅ ២០% លើមុខទំនិញរថយន្តដឹកជញ្ជូនទំនិញនៅឃ្លាំង ឬទីលាន និងរ៉ឺម៉កសណ្តោង ចំនួន ០៧ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមានក្នុងទីតាំងរងលេខ ៨៧០៤.១៩.០០ ៨៧១៦.១០.០០ ៨៧១៦.៣១.០០ ៨៧១៦.៣៩.៩១ ៨៧១៦.៣៩.៩៩ ៨៧១៦.៤០.០០ និងទីតាំងរងលេខ ៨៧១៦.៨០.៩០។

មាត្រា ៩.- ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញគ្រឿងបន្លាស់យានយន្តមួយចំនួន ដូចខាងក្រោម÷

- ដំឡើងពី ១០% ទៅ ១៥% លើមុខទំនិញគ្រឿងបន្លាស់ទោចក្រយានយន្ត ចំនួន ១៨ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៤០៧.៣២.១២ ៨៤០៧.៣២.២២ ៨៧១៤.១០.១០ ៨៧១៤.១០.២០ ៨៧១៤.១០.៩០ ៨៧១៤.៩១.៩១ ៨៧១៤.៩១.៩៩ ៨៧១៤.៩២.៩០ ៨៧១៤.៩៣.៩០ ៨៧១៤.៩៤.៩០ ៨៧១៤.៩៥.៩០ ៨៧១៤.៩៦.៩០ ៨៧១៤.៩៩.៩១ និងទីតាំងរងលេខ ៨៧១៤.៩៩.៩២។
- ដំឡើងពី ១០% ទៅ ២០% លើមុខទំនិញគ្រឿងបន្លាស់យានយន្ត ០៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៧០៩.៩០.០០ ៨៧១៦.៩០.១៣ និងទីតាំងរងលេខ ៨៧១៦.៩០.១៩។
- ដំឡើងពី ១០% ទៅ ២៥% លើមុខទំនិញគ្រឿងបន្លាស់រថយន្ត ចំនួន ០៤ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៤០៧.៣២.១១ ៨៤០៧.៣២.១៩ ៨៤០៧.៣២.២១ និងទីតាំងរងលេខ ៨៤០៧.៣២.២៩ ។

ជំពូកទី ៣
អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
សូមហត្ថលេខា
ឧបមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការវាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ជូនចមាត្រា ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ